# ការសម្ភាសន៍របស់អ្នកមីង ប៉ុល តួយ

កៈ អ្នកសំភាសន៍ គង់ ចាន់ណាក់ ខៈ អ្នកដែលត្រូវបានគេសំភាសន៍ឈ្មោះ ប៉ុល តួយ

**<u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ ប៉ុល តួយ</u>**

ធ្វើឡើងនៅភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ធ្វើឡើងនៅថ្ងៃទី២៩ ខែ០៦ ឆ្នាំ២០១៨។សង្ខេបៈ អ្នកមីង ប៉ុល តួយ គាត់មានអាយុហុកសិបប្រាំឆ្នាំ ហើយគាត់បានកើតនៅភូមិធ្លក ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ហើយគាត់មានបងប្អូនចំនួនបួននាក់ តែបានស្លាប់អស់ពីរនាក់ហើយ នៅសល់តែពីរនាក់ទេ ហើយគាត់ជាកូនទីពីរ។ ហើយប្អូនរបស់គាត់មួយបានស្លាប់នៅសមរភូមិពេលគាត់ទៅធ្វើជាទ័ពក្នុងសម័យសង្គ្រាម ពលពត ហើយប្អូនមួយទៀតរបស់គាត់បានស្លាប់ពេលគាត់បានទៅធ្វើជំនួញគោ ពេលគាត់ត្រឡប់មកពីស្រុកយួនវិញ មកជិតដល់ផ្ទះចោរប្លន់ហើយស្លាប់គាត់នឹងកូនរបស់គាត់។ សំរាប់អ្នកមីងគាត់មានការលំបាកច្រើន ឪពុកម្តាយរបស់គាត់បានស្លាប់តាំងពីគាត់នៅក្មេងដូច្នេះគាត់ត្រូវនៅជាមួយជីដូនជីតា ហើយប្អូនគាត់បានស្លាប់ចោលគាត់ទៀត។ នៅក្នុងជំនាន់ពលពតគេអោយគាត់នៅដាក់បាយអោយជ្រូកហើយទា គេយើងតែគាត់ដាក់បាយប៉ុណ្ណោះ មិនអោយរើសពងទាឡើងបើគេចាប់បានគេយកទៅវាយចោស។ ហើយសំរាប់សព្វថ្ងៃនេះគាត់មានជីវភាពធូរស្រាលច្រើនដោយសារមានកូនទៅស៊ីឈ្នួលគេ នៅប្រទេសថៃហើយបានជួយផ្គត់ផ្គង់ដល់គាត់ ហើយគាត់មានពេលវេលាច្រើនសំរាប់ធ្វើបុណ្យ។

កៈ ដំបូងជំរាបសួរអ្នកមីង ខ្ញុំឈ្មោះ គង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ ប្រជាជនកម្ពុជាដែលគម្រោងនឹងធ្វើឡើងដោយសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិច ដែល មានឈ្មោះ សាកលវិទ្យាល័យ ប៊ី វ៉ាយ យ៉ូ ដោយសារសាកលវិទ្យាល័យគាត់មានគម្រោងដើម្បីជួយ ថែរក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរដើម្បីទុកអោយកូនចៅជំនាន់ក្រោយគាត់អាចរៀនហើយ

ស្គាល់ពី ប្រវត្តិរបស់ជីដូនជីតាហើយនឹងឪពុកម្ដាយ។ ហើយអញ្ចឹង សំរាប់ការសម្ភាសន៍យើងនឹងធ្វើឡើងនៅ ភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃុំ។ ហើយសំរាប់ការសម្ភាសន៍នឹងយើងធ្វើនៅ ថ្ងៃទី២៩ ខែ០៦ ឆ្នាំ២០១៨។ ហើយអញ្ចឹងសំរាប់ការសម្ភាសន៍នឹងយើងនឹងថតជាសំលេងនឹងថត រូបភាពដើម្បីយើងអាចយក សំលេងហើយនឹងរូបភាពនឹងផ្ញើរទៅកាន់សាកលវិទ្យាល័យដើម្បីគេ អាចដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹង តើអ្នកមីងយល់ព្រមដើម្បីយើង យកសំលេងហើយនឹងរូបថតរបស់អ្នកមីងដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យដែរទេ អ្នកមីង?

ខ៖ ព្រម។

ក៖ អញ្ចឹង អរគុណអ្នកមីងដែលយល់ព្រមអោយយើងយកសំលេងហើយនឹងរូបភាពរបស់អ្នកមីង ដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹងជាដំបូងសុំសួរអ្នកមីងថា តើអ្នកមីង មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ខ្ញុំឈ្មោះ ប៉ុល តូយ។

ក៖ អ្នកមីងឈ្មោះ ប៉ុល តូយ! ហើយអញ្ចឹងសំរាប់អ្នកមីងមានឈ្មោះហៅក្រៅដែរទេ អ្នកមីង?

ខ៖ អត់មានទេ គេហៅអញ្ចឹងរហូតតែម្ដង។

ក៖ ហើយអញ្ចឹង កាលពីនៅក្មេងៗ តើគេហៅឈ្មោះរបស់អ្នកមីងថាម៉េចដែរ អ្នកមីង?

ខ៖ គេហៅអញ្ចឹងតែម្ដង ឈ្មោះតែមួយនឹងទេ ព្រោះឈ្មោះមួយទៀតនឹងគេអត់ហៅកើតឡើងវាឈឺពេកទៅ គេហៅថាចឹងរហូតទៅ។

ក៖ អញ្ចឹង អ្នកមីងមានឈ្មោះមួយទៀត តែឈឺពេក។

ខ៖ តែឈឺពេក អញ្ចឹងគេអត់យកទេឈ្មោះនឹង គេយកឈ្មោះរាល់ថ្ងៃនឹងទៅ។

ក៖ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះ តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ខ្ញុំអាយុហុកសិបប្រាំឆ្នាំហើយ។

កៈ អ្នកមីងអាយុហុកសិបប្រាំឆ្នាំហើយ! ហើយអញ្ចឹង តើអ្នកមីងមាននៅចាំថា អ្នកមីងបានកើតនៅក្នុងឆ្នាំណាទេ អ្នកមីង?

ខៈ អត់ចាំផង។

កៈ អ្នកមីងអាយុហុកសិបប្រាំឆ្នាំ អញ្ចឹងអ្នកមីងប្រហែលជាកើតក្នុងឆ្នាំមួយពាន់ប្រាំបួនរយសាសិបបី។ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងបានកើតក្នុងឆ្នាំខ្មែរយើងឆ្នាំអ្វីដែរ អ្នកមីង?

ខៈ ខ្ញុំកើតឆ្នាំមមី។

កៈ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងបានកើតនៅកន្លែងណាដែរ អ្នកមីង?

ខៈ ខ្ញុំកើតនៅភូមិធ្លក ឃុំដំរិលដែរ។

កៈ ភូមិធ្លក ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ហើយអញ្ចឹងសំរាប់អ្នកមីង តើអ្នកមីងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរ អ្នកមីង?

ខៈ ខ្ញុំមានបងប្អូនចំនួនបួននាក់ តែស្លាប់អស់ហើយនៅសល់តែពីរនាក់ទេ។

កៈ អូ! បងប្អូនរបស់អ្នកមីងមានបួននាក់តែស្លាប់អស់ពីរនាក់ហើយនៅសល់តែពីរនាក់ទេ។ ហើយអញ្ចឹង តើអ្នកមីងជាកូនទីប៉ុន្មាននៅក្នុងក្រុមគ្រួសារ អ្នកមីង?

ខៈ ខ្ញុំជាកូនទីពីរ។

កៈ អូ! អ្នកមីងជាកូនទីពីរ! ហើយអញ្ចឹង តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះបងប្អូនរបស់អ្នកមីងទាំងបួននាក់បានទេ អ្នកមីង?

ខៈ បងទីមួយឈ្មោះពឿន បន្ទាប់មកខ្ញុំនឹង ហើយបន្ទាប់ទៀតឈ្មោះ សុាំង ហើយមកមួយទៀតឈ្មោះសារឿន។

កៈ អូ! ពៅគេឈ្មោះសារឿន! ហើយអញ្ចឹងបងប្អូនរបស់អ្នកមីងទាំងពីរនាក់ដែលស្លាប់នឹងជាកូនទីប៉ុន្មានខ្លះដែរ អ្នកមីង?

ខៈ ទីបីនឹងទីបួន។

កៈ អូ! អញ្ចឹងប្អូនរបស់អ្នកមីងទាំងពីនាក់នឹងស្លាប់ទាំងអស់។ ហើយអញ្ចឹងប្អូនរបស់អ្នកមីងទាំងពីរនាក់នឹង តើពួកគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ អ្នកមីង?

ខ៖ ប្អូនខ្ញុំស្លាប់ពៅគេនឹងស្លាប់ដោយសារទៅទ័ព។

ក៖ អូ! គាត់ទៅទ័ពជំនាន់ពលពត មែនទេ អ្នកមីង?

ខ៖ ហ្នឹងហើយ! ជំនាន់នឹង ហើយទីបីនឹងស្លាប់ដោយសារគេប្លន់។

ក៖ អូ! គេប្លន់នៅនឹងផ្ទះ មែនទេ អ្នកមីង?

ខ៖ គេប្លន់ពេលទៅជំនួញគោ ពេលមកពីស្រុកយួនវិញ
មកជិតដល់ភូមិវិញហើយគេប្លន់តាមផ្លូវ គេសំលាប់ចោលទាំងឪពុកទាំងកូន។

ក៖ អូ! អញ្ចឹងទាំងឪពុករបស់អ្នកមីងដែរ មែនទេ?

ខ៖ អត់ទេ កូនរបស់ប្អូនខ្ញុំនឹងណា។

ក៖ អូ! គាត់មានកូនហើយគេសំលាប់ទាំងពីរនាក់ឪកូននឹង។
ហើយអញ្ចឹងពេលដែលគេសំលាប់គាត់នឹងប្រហែលជាឆ្នាំណាដែរ អ្នកមីងមាននៅចាំទេ?

ខ៖ គេសំលាប់គាត់នឹងនៅឆ្នាំវក។

ក៖ ហើយអញ្ចឹង គេសំលាប់គាត់នឹងប្រហែលប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ប្រហែលដប់បួនឆ្នាំហើយ។

ក៖ អូ! ប្រហែលដប់បួនឆ្នាំហើយ យូរដែលហើយអ្នកមីង។
ហើយអញ្ចឹងសំរាប់បងរបស់អ្នកមីងដែលគាត់នៅរស់នឹង
តើសព្វថ្ងៃនេះគាត់រស់នៅកន្លែងណាដែរ អ្នកមីង?

ខ៖ បងរបស់ខ្ញុំសព្វថ្ងៃនេះគាត់រស់នៅខេត្តកំពង់ឆ្នាំង។
គាត់ក៏មិនសូវព្វកែដែលព្រោះកាលជំនាន់ធ្វើទ័ពនឹងគ្រាប់បែកវាត្រូវគាត់
អញ្ចឹងហើយគាត់មិនសូវមាំមួនទេច្រើនតែភ្លេចៗ។

ក៖ អូ! អញ្ចឹងគាត់ត្រូវគ្រាប់! ហើយអញ្ចឹង តើគាត់រស់នៅខេត្តកំពង់ឆ្នាំងនឹង
គាត់ធ្វើការងារអ្វីដែរ អ្នកមីង?

ខ៖ ទេគ្មានធ្វើអីទេ តានឹងនៅជាមួយយាយនឹងមើលតែចៅ។

ក៖ មើលចៅ អញ្ចឹងកូនចៅគាត់រកស៊ីចិញ្ចឹម។ ហើយអញ្ចឹង កាលពីនៅក្មេងៗ
តើអ្នកមីងចូលចិត្តធ្វើអ្វីខ្លះជាមួយបងប្អូនរបស់អ្នកមីងដែរ?

ខ៖ ចូលចិត្តរកស៊ីជាមួយបងប្អូន គ្មានឈ្លោះគ្មានប្រកែកគ្នាទេ។

ក៖ ដូចជាធ្វើស្រែធ្វើចំការជាមួយគ្នា! ហើយអញ្ចឹង សំរាប់ម្តាយរបស់អ្នកមីង
តើគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ឈ្មោះ បក់ អួន។

ក៖ ម្តាយរបស់អ្នកមីងឈ្មោះ បក់ អួន។ ហើយអញ្ចឹងសំរាប់សព្វថ្ងៃនេះ
តើម្តាយរបស់អ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ស្លាប់យូរហើយ គាត់ស្លាប់តាំងពីខ្ញុំអាយុដប់ពីរឆ្នាំម្លេះ។

ក៖ អូ! ពេលគាត់ស្លាប់នឹងអ្នកមីងមានអាយុដប់ពីរឆ្នាំ។

ខ៖ ហ្នឹងហើយ!

ក៖ ហើយអញ្ចឹងសំរាប់ម្តាយរបស់អ្នកមីង តើគាត់មានស្រុកកំណើតនៅកន្លែងណាដែរ
អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់កើតនៅនឹងភូមិធ្លក ឃុំដំរិល តែម្តង។

ក៖ អូ! នៅភូមិធ្លក ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ហើយអញ្ចឹង
ពេលដែលម្តាយរបស់អ្នកមីងគាត់ស្លាប់នឹង ប្រហែលជាឆ្នាំណាដែរ អ្នកមីងមាននៅចាំទេ?

ខ៖ ខ្ញុំអត់ចាំទេ។

ក៖ ហើយអញ្ចឹង តើម្តាយរបស់អ្នកមីងគាត់ស្លាប់មុនសម័យពលពត
ឬមួយក្រោយសម័យពលពត ទេ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ស្លាប់មុនសម័យពលពត។

ក៖ ហើយអញ្ចឹង ពេលដែលម្តាយរបស់អ្នកមីងគាត់ស្លាប់នឹង
តើគាត់មានអាយុប៉ុន្មានឆ្នាំដែរ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ទើបតែអាយុសាជាងនឹង។

ក៖ គាត់ទើបតែអាយុហាជាងទេ ហើយកាលនឹងអ្នកមីងអាយុដប់ពីរឆ្នាំ។ ហើយអញ្ចឹង
កាលដែល  ម្តាយរបស់អ្នកមីងគាត់នៅរស់នឹង តើគាត់រកស៊ីអ្វីដែរ អ្នកមីង?

ខ៖ ម្តាយរបស់ខ្ញុំគាត់ធ្វើស្រែ។

កៈ ហើយអញ្ចឹង សំរាប់ម្ដាយរបស់អ្នកមីងគាត់មានចរិតយ៉ាងដូចម្ដេចដែរ អ្នកមីង?

ខៈ ចរិតគាត់ស្លូតបូត មិនដែលមានមាត់ធំមាត់តូចជាមួយអ្នកណាគេទេ
គាត់ស្លូតបូតអ្នកស្រុកចូលចិត្តគាត់ណាស់។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់ឈ្មោះ ប៉ុល សំ។

កៈ ឪពុករបស់អ្នកមីងឈ្មោះ ប៉ុល សំ! ហើយអញ្ចឹង សព្វថ្ងៃនេះ
តើឪពុករបស់អ្នកមីងគាត់មានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ ទេ មិនដឹងគាត់អាយុប៉ុន្មានទេបើគាត់ស្លាប់បាត់ដែរហើយ។

កៈ អូ! គាត់ស្លាប់បាតហើយ!

ខៈ ហ្នឹងហើយ! គាត់ស្លាប់មុនម្ដាយរបស់ខ្ញុំទៀត។

កៈ អូ! គាត់ស្លាប់មុនម្ដាយរបស់អ្នកមីងទៀត។ ហើយអញ្ចឹង
តើឪពុករបស់អ្នកមីងគាត់បានកើតនៅកន្លែងណាដែរ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់កើតនៅភូមិត្រពាំងទា ឃុំចក។

កៈ ភូមិត្រពាំងទា ឃុំចក។ ហើយស្រុកណាដែរ អ្នកមីង?

ខៈ ស្រុកអូររាំងឪដែរនឹង ឃុំចក។

កៈ ហើយអញ្ចឹង ពេលដែលឪពុករបស់អ្នកមីងគាត់បានស្លាប់
តើគាត់ស្លាប់នៅកន្លែងណាដែរ អ្នកមីង?

ខៈ ឪពុករបស់ខ្ញុំគាត់បានស្លាប់នៅនឹងភូមិធ្លក។

កៈ អូ! ឪពុករបស់អ្នកមីងគាត់ស្លាប់នៅនឹងភូមិធ្លក។ ហើយអញ្ចឹង
ពេលដែលឪពុករបស់អ្នកមីងគាត់បានស្លាប់នឹង តើគាត់មានអាយុប៉ុន្មានឆ្នាំហើយ អ្នកមីង?

ខៈ ពេលឪពុកខ្ញុំស្លាប់នឹងគាត់អាយុជាងសាសិបឆ្នាំនឹង គាត់ឈឺអត់មានស្អីទេឈឺតែម្ដង
ឈឺរីងរ៉ៃមិនអត់ជា ដេកពេទ្យធ្លាក់ដល់កំពង់ចាមពីដើមនឹង មើលអត់ជាក៏ស្លាប់ទៅ។

កៈ ហើយអញ្ចឹង ពេលដែលឪពុករបស់អ្នកមីងគាត់នៅរស់
តើគាត់ធ្វើការងារអ្វីដើម្បីចិញ្ចឹមជីវិតដែរ អ្នកមីង?

ខ៖ ឪពុករបស់ខ្ញុំគាត់ធ្វើស្រែ។

ក៖ ហើយអញ្ចឹង តើឪពុករបស់អ្នកមីងគាត់ជាមនុស្សបែបណាដែរ ចរិតរបស់គាត់ណា អ្នកមីង?

ខ៖ មនុស្សគាត់ស្លូតបូតនឹង ដូចគ្នានឹងម៉ែនឹងដែរ។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង
តើអ្នកមីងធ្លាប់មានអនុស្សាវរីយ៍អ្វីល្អៗជាមួយនឹងឪពុកម្ដាយរបស់អ្នកមីងដែរឬទេ?

ខ៖ មានល្អៗដូចថា
ពេលនៅតូចគាត់ប្រើអោយធ្វើអីមិនប្រកែកមិនប្រណាំងនឹងគាត់ធ្វើតាមគាត់។

ក៖
ហើយអញ្ចឹងសំរាប់ឪពុកម្ដាយរបស់អ្នកមីងគាត់ធ្លាប់ប្រាប់អ្នកមីងពីជីវិតគាត់កាលគាត់នៅក្មេងៗទេ អ្នកមីង?

ខ៖ ធ្លាប់ ជីវិតាគាត់តែនឹងជម្ងឺនឹងតែម្ដង ឈឺរុំារ៉ៃមិនឈប់មិនឈរទល់នឹងស្លាប់។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង
តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់អ្នកមីងទេ?

ខ៖ ជីដូនជីតាខាងម្ដាយរបស់ខ្ញុំគាត់ឈ្មោះ តាប៉ក់ យាយឆែម។

ក៖ ហើយអញ្ចឹង តើជីដូនជីតាខាងម្ដាយរបស់អ្នកមីងគាត់កើតនៅកន្លែងណាដែរ អ្នកមីង?

ខ៖ ជីដូនជីតាខាងម្ដាយរបស់ខ្ញុំគាត់កើតនៅភូមិធ្លក។

ក៖ ហើយអញ្ចឹង តើជីដូនជីតាខាងម្ដាយរបស់អ្នកមីងពួកគាត់កើតនៅពេលណា អ្នកមីងមាននៅចាំទេ?

ខ៖ អត់ចាំទេ។

ក៖ ហើយអញ្ចឹង តើជីដូនជីតាខាងម្ដាយរបស់អ្នកមីងពួកគាត់បានស្លាប់ពេលណា អ្នកមីងមាននៅចាំទេ?

ខ៖ ស្លាប់អត់ចាំទេ ភ្លេចឆ្នាំទៅហើយ។

ក៖ ហើយអញ្ចឹង តើជីដូនជីតាខាងម្ដាយរបស់អ្នកមីងពួកគាត់បានស្លាប់នៅកន្លែងណាដែរ អ្នកមីង?

ខ៖ ពួកគាត់ស្លាប់នៅនឹងភូមិធ្លក ពេលយើងមកពីកៀរវិញមិនដឹងជាឆ្នាំចិតសិបប៉ុន្មានទេ។

ក៖ អូ! គាត់ស្លាប់ពេលមកពីឆ្នាំកៀរនឹងតែម្តង។

ខ៖ ហ្នឹងហើយ! ពេលមកពីកៀរវិញហើយបានគាត់ស្លាប់សំរាប់តា
ហើយបើយាយគាត់ស្លាប់មុន។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីង
តើពេលអ្នកមីងកើតមកបានជួបជាមួយគាត់ហើយបាននៅជាមួយគាត់ខ្លះទេ អ្នកមីង?

ខ៖ ខ្ញុំបាននៅជាមួយតាពេលអត់ពីម៉ែពីឪទៅនៅជាមួយតា។

ក៖ អញ្ចឹង ឪពុកម្តាយរបស់អ្នកមីងគាត់បានស្លាប់មុន ហើយតាគាត់ស្លាប់ក្រោយទេ។

ខ៖ ហ្នឹងហើយ! តាហើយយាយគាត់ស្លាប់ក្រោយតើ។

ក៖ អញ្ចឹងបាននៅជាមួយគាត់ គាត់ជួយថែរក្សាយើងទៅ។ ហើយអញ្ចឹង
តើអ្នកមីងមាននៅចាំឈ្មោះជីដូនជីតាខាងឪពុករបស់អ្នកមីងទេ?

ខ៖ ជីដូនជីតាខាងឪពុករបស់ខ្ញុំគាត់ឈ្មោះ តាសូ យាយសំ។

ក៖ ហើយអញ្ចឹង តើជីដូនជីតាខាងឪពុករបស់អ្នកមីងពួកគាត់បានកើតនៅកន្លែងណា
អ្នកមីងមាននៅចាំទេ?

ខ៖ ជីដូនជីតាខាងឪពុករបស់ខ្ញុំគាត់កើតនៅភូមិត្រពាំងទា ឃុំចក។

ក៖ ហើយអញ្ចឹង តើជីដូនជីតាខាងឪពុករបស់អ្នកមីងពួកគាត់បានកើតនៅពេលណា
អ្នកមីងមាននៅចាំទេ?

ខ៖ អត់ចាំទេ។

ក៖ ហើយអញ្ចឹង តើជីដូនជីតាខាងឪពុករបស់អ្នកមីងពួកគាត់បានស្លាប់ពេលណា
អ្នកមីងមាននៅចាំទេ?

ខ៖ មិនចាំ។
ក៖ ហើយអញ្ចឹង តើជីដូនជីតាខាងឪពុករបស់អ្នកមីងពួកគាត់ស្លាប់នៅកន្លែងណាដែ
អ្នកមីង?

ខ៖ ដឹងតែថាគាត់ស្លាប់នៅភូមិត្រពាំងទានឹងតែម្តង។

ក៖ អូ! គាត់ស្លាប់នៅនឹងភូមិត្រពាំងទានឹងតែម្តង។ ហើយអញ្ចឹង
តើអ្នកមីងធ្លាប់ជួបជាមួយជីដូនជីតាខាងឪពុករបស់អ្នកមីងទេ?

ខ៖ លែងចាំហើយគាត់យូរហើយ។

ក៖ តែអ្នកមីងអត់ចាំថាបានជួបជាមួយឬអត់ទេ។

ខ៖ គ្រាន់តែចាំឈ្មោះ ចាំឈ្មោះដល់ឥលូវនឹងពេលខែបុណ្យខែទានចេះតែហៅទៅ។

ក៖ ចាំឈ្មោះគាត់
យើងធ្វើបុណ្យធ្វើទានយើងហៅឈ្មោះគាត់ទៅអោយគាត់បានទទួលបុណ្យទានពីយើងចឹងទៅ។
ហើយអញ្ចឹងសំរាប់ក្រុមគ្រួសាររបស់អ្នកមីងរស់នៅខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ
អ្នកមីង?

ខ៖ នៅយូរដែរហើយ តាំងពីអាយុដប់ប្រាំពីរឆ្នាំ ហើយឥលូវអាយុហុកសិបប្រាំឆ្នាំហើយ។

ក៖ អូ! ពេលអ្នកមីងអាយុដប់ប្រាំពីរឆ្នាំមករស់នៅភូមិនឹង។

ខ៖ ហ្នឹងហើយ! រៀបការហើយមករស់នៅនឹងពេលអាយុដប់ប្រាំពីរឆ្នាំ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានសាច់ញាតិដទៃដែលរស់នៅក្រៅប្រទេសខ្មែរទេ អ្នកមីង?

ខ៖ អត់មានទេ មានតែកូនទៅស៊ីឈ្នួលគេនៅប្រទេសថៃនឹង។

ក៖ ហើយអញ្ចឹងសំរាប់ស្វាមីរបស់អ្នកមីង តើគាត់មានឈ្មោះអ្វីដែរ អ្នកមីង?

ខ៖ ស្វាមីរបស់ខ្ញុំគាត់ឈ្មោះ គង់ គិត។

ក៖ ស្វាមីរបស់អ្នកមីងឈ្មោះ គង់ គិត! ហើយអញ្ចឹង
តើអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ពេលណាដែរ អ្នកមីង?

ខ៖ ខ្ញុំរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅឆ្នាំចិតគត់។

ក៖ អូ! អ្នកមីងអាពាហ៍ពិពាហ៍ជាមួយគាត់នៅឆ្នាំចិតគត់ អញ្ចឹងមុនសម័យពលពត។

ខ៖ ចាំ! មុនសម័យពលពត។

ក៖ ហើយអញ្ចឹង ពេលដែលអ្នកមីងរៀបអាពាហ៍ពិពាហ៍នឹង
តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ពេលរៀបអាពាហ៍ពិពាហ៍នឹងខ្ញុំអាយុដប់ប្រាំពីរឆ្នាំ។

ក៖ អូ! អ្នកមីងអាយុដប់ប្រាំពីរឆ្នាំ។ ហើយអញ្ចឹង
តើអ្នកមីងរៀបអាពាហ៍ពិពាហ៍ជាមួយគាត់នៅកន្លែងណាដែរ អ្នកមីង?

ខ៖ នៅឯភូមិធ្លកនឹង។

ក៖ អូ! រៀបអាពាហ៍ពិពាហ៍នៅភូមិធ្លកទេ ហើយបាននាំគ្នាមកនៅភូមិនេះវិញ។

ខ៖ ហ្នឹងហើយ! រៀបការហើយបានមកនៅនឹង។

ក៖ រៀបការបានប៉ុន្មានឆ្នាំបានប្តូរផ្ទះមកនៅភូមិនេះវិញ?

ខ៖ រៀបការហើយបានបីថ្ងៃ ប្តីយកមកនៅភូមិនឹង។

ក៖ អូ! អញ្ចឹងប្តីរបស់អ្នកមីងគាត់ជាអ្នកស្រុកភូមិក្បាលអូរយើងនឹង
ហើយដល់រៀបការហើយបានបីថ្ងៃគាត់នាំអ្នកមីងមកនៅទីនេះ
មកនៅជុំគ្នានៅទីនេះវិញហើយក៏មកនៅរហូតដល់ឥលូវទៅ។ ហើយអញ្ចឹងសព្វថ្ងៃនេះ
តើប្តីរបស់អ្នកមីងគាត់រស់នៅកន្លែងណាដែរ អ្នកមីង?

ខ៖ ប្តីរបស់ខ្ញុំគាត់ស្លាប់បាត់ហើយ។

ក៖ អូ! គាត់ស្លាប់បាត់ហើយ!

ខ៖ គាត់ស្លាប់ប្រាំបួនឆ្នាំហើយ។

ក៖ អូ! គាត់បានស្លាប់ប្រាំបួនឆ្នាំហើយ អ្នកមីង។ ហើយអញ្ចឹង
តើគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ អ្នកមីង?

ខ៖ គាត់ដេក ដឹងយ៉ាងម៉េច ខ្យល់ឬយ៉ាងម៉េច គាត់ស្លាប់អត់ដឹងផងនឹង។

ក៖ អូ! គាត់អត់មានឈឺអីពីមុនទេ?

ខ៖ អត់មានឈឺអីទេ ហូបបាយពីរបីពេលថ្ងៃនឹងនោះ
ហើយដល់យប់ដេកហើយដល់ម៉ោងបីខ្ញុំដាស់ទៅ គាត់ដាច់ខ្យល់ហើយនឹង។

ក៖ ហើយអញ្ចឹង សំរាប់អ្នកមីងហើយលោកពូជួបគ្នាដំបូងនៅពេលណាដែរ អ្នកមីង?

ខ៖ ជួបគ្នាដំបូងនៅឆ្នាំចិតគត់នឹងណា។

ក៖ មិនដែលស្គាល់គ្នាទេ ឬក៏យ៉ាងម៉េចដែរ អ្នកមីង?

ខ៖ មិនដែលស្គាល់គ្នាទេ។

ក៖ ឪពុកម្ដាយគាត់នាំមកតែម្ដង។

ខ៖ ហ្នឹងហើយ! មិនដែលស្គាល់ទេ គេចូលស្ដីរៀបការតែម្ដង។

ក៖ ហើយអញ្ចឹង អាពាហ៍ពិពាហ៍នឹងរៀបចំឡើងដោយឪពុកម្ដាយ ឬមួយយ៉ាងម៉េចដែរ អ្នកមីង?

ខ៖ ប្ដីរបស់ខ្ញុំគាត់មានម៉ែ ហើយខ្ញុំមានយាយតា។

ក៖
អញ្ចឹងមានន័យថាអាពាហ៍ពិពាហ៍នឹងយាយតារបស់អ្នកមីងគាត់ជាអ្នកជួយរៀបចំអោយ។ ហើយអញ្ចឹងសំរាប់អាពាហ៍ពិពាហ៍របស់អ្នកមីង តើមានកូនចំនួនប៉ុន្មាននាក់ដែរ អ្នកមីង?

ខ៖ កូនរបស់ខ្ញុំនៅប្រាំមួយនាក់។

ក៖ តែទាំងអស់ប៉ុន្មាននាក់ទេ បើរាប់ទាំងអស់ទាំងអ្នកដែលស្លាប់ដែរ?

ខ៖ ស្លាប់ពីរនាក់ ទាំងអស់ប្រាំបីនាក់។

ក៖ អញ្ចឹង អ្នកមីងមានកូនទាំងអស់ប្រាំបីនាក់។ ហើយអញ្ចឹង តើអ្នកមីងអាចជួយរៀបរាប់ឈ្មោះកូនរបស់អ្នកមីងទាំងប្រាំនាក់បានទេ អ្នកមីង?

ខ៖ បងគេឈ្មោះសុខ បន្ទាប់មកឈ្មោះសឹង មួយទៀតនឹងឈ្មោះសយ ស្លាប់ដែរហើយ បន្ទាប់មកទៀតនឹងឈ្មោះសៀម បន្ទាប់មកទៀតឈ្មោះច្រឹប បន្ទាប់មកទៀតឈ្មោះផល ហើយបន្ទាប់មកទៀតឈ្មោះខូច
ហើយបន្ទាប់មកទៀតប្រុសអត់មានដាក់ឈ្មោះទេស្លាប់តែម្ដង កើតបានកន្លះខែ។

ក៖ អូ! អញ្ចឹងកើតបានតែកន្លះខែស្លាប់ទៅ។ ហើយចុះមួយបងដែលស្លាប់ដែរនឹង តើគាត់បានស្លាប់ដោយសារមូលហេតុអ្វីដែរ អ្នកមីង?

ខ៖ ឈឺមកពីកៀរវិញមើលអត់ជាស្លាប់តែម្ដង។

ក៖ ប្រហែលមកពីហូបអត់គ្រប់គ្រាន់។

ខ៖ ថ្នាំវាមិនគ្រប់គ្រាន់។

ក៖ ហ្នឹងហើយ! វាអត់សំបូរថ្នាំដូចស្រុកឥលូវ។

ខ៖ វាមិនសំបូរថ្នាំឯណា លេបតែថ្នាំសូន្យសូន្យនឹងនោះ អត់ជា។

ក៖ ឈឺធ្ងន់ទៅៗ ស្លាប់ទៅ។ ហើយអញ្ចឹងសំរាប់កូនរបស់អ្នកមីងទាំងប្រាំមួយនាក់នឹង តើរៀបការបានប៉ុន្មាននាក់ហើយ អ្នកមីង?

ខ៖ រៀបការអស់ហើយ។

ក៖ អូ! រៀបការហើយទាំងប្រាំមួយនាក់តែម្តង។
ហើយអញ្ចឹងសំរាប់អ្នកមីងសព្វថ្ងៃនេះមានចៅចំនួនប៉ុន្មាននាក់ហើយ អ្នកមីង?

ខ៖ ខ្ញុំមានចៅចំនួនដប់នាក់ហើយ។

ក៖ អូ! ចៅច្រើនណាស់។ ហើយអញ្ចឹងសំរាប់អ្នកមីង
តើអ្នកមីងចេះអាននិងសរសេរអក្សរខ្មែរទេ អ្នកមីង?

ខ៖ អូ! អត់ចេះទេ។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីងចេះនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទេ អ្នកមីង?

ខ៖ អត់ចេះទេ។

ក៖ ហើយអញ្ចឹង តើអ្នកមីងមានបានចូលសាលារៀនទេ អ្នកមីង?

ខ៖ គ្មានបានចូលទេសាលារៀនរវល់មើលក្របី ចង់ទៅរៀនណាស់តែជាប់មើលក្របី អត់បានទៅរៀននឹងគេ។

ក៖ ហើយអញ្ចឹងសំរាប់អ្នកមីងមានមិត្តភក្តិជិតស្និតទេ អ្នកមីង?

ខ៖ គ្មានទេមិត្តភក្តិ មានតែបងប្អូននៅជិតខាង។

ក៖ អ្នកមីងមានតែបងប្អូនជិតខាងរាប់អានធម្មតា តែបើមិត្តភក្តិជិតស្និតគ្មានទេ។
ហើយអញ្ចឹងរាល់ថ្ងៃនេះអ្នកមីងមានធ្វើស្រែចំការទេ អ្នកមីង?

ខ៖ អត់មានធ្វើនឹងគេទេរាល់ថ្ងៃនេះ កូនវាទៅប្រទេសថៃអស់ហើយនោះ។

ក៖ ហើយអញ្ចឹង តើរាល់ថ្ងៃនេះអ្នកមីងបានអីដើម្បីចិញ្ចឹមជីវិតដែរ អ្នកមីង?

ខ៖ ជួលស្រែរបស់ខ្ញុំនឹងអោយកូនចៅគេធ្វើហើយគេអោយបន្តិចបន្តួចមកហូបទៅ។

ក៖ យកស្រែយើងទៅជួលអោយគេធ្វើ។

ខ៖ ហ្នឹងហើយ! គេធ្វើទៅហើយគេអោយឈ្នួលនឹងមក គ្រាន់នឹងហូបរាល់ថ្ងៃនឹងណា ហើយកូនចៅគេផ្ញើរមកខ្លះទៀតទៅ អោយកូនចៅគេរៀនគេសូត្រនឹង។

ក៖ ហ្នឹងហើយ! យើងនៅជួយមើលកូនអោយគេទេ។

ខ៖ ហ្នឹងហើយ! ចៅនៅពីរនាក់រាល់ថ្ងៃនឹង។

ក៖ ជួយមើលខុសត្រូវ អោយទៅរៀនទៅសូត្រ
ហើយធ្វើអីអោយគាត់ហូបដាំបាយដាំទឹកអោយ   ហូប។ ហើយអញ្ចឹង
សំរាប់អ្នកមីងគិតថាជីវិតរបស់អ្នកមីងតាំងពីក្មេងរហូតមកដល់ពេលនេះ
តើជីវិតរបស់អ្នកមីងមានការផ្លាស់ប្តូរទេ អ្នកមីង?

ខ៖ វាផ្លាស់ប្តូរហើយ ពិបាកណាស់ពីមុនមហាស្តេចពិបាកហើយ តែឥលូវនឹងវាធូរបន្តិច។

ក៖ ហើយអញ្ចឹង តើមានម្ហូបណាដែលអ្នកមីងចូលចិត្តហូបជាងគេទេ អ្នកមីង?

ខ៖ អូ! ស្អីក៏ហូបបានដែរអោយតែមាន។

ក៖ អត់សូវប្រកាន់ទេ។

ខ៖ អត់ប្រកាន់ទេ។

ក៖ ហើយអញ្ចឹងសំរាប់ល្បែងប្រជាប្រិយខ្មែរដូចជា បោះឈូង បោះអង្គញ់ ទាញព្រ័ត្រអី ពីក្មេងៗអ្នកមីងមានចូលចិត្តលេងអីទេ អ្នកមីង?

ខ៖ ពីក្មេងលេង នោះហើយលេងសប្បាយ
ចាស់នឹងហើយក៏លេងដែរខែចូលឆ្នាំលោកអោយលេងបីថ្ងៃចូលឆ្នាំនឹង
ទាំងគេទាំងឯងលេងទៅទាញព្រ័ត្រអីទៅ ។

ក៖ ហ្នឹងហើយ! សប្បាយ
ដោយសារវាមិនមែនជាល្បែងស៊ីសងអីផងវាជាល្បែងប្រពៃណីខ្មែរយើងពីដូនតាមក។
ហើយអញ្ចឹង តើមានបទចម្រៀងណាដែលអ្នកមីងចូលចិត្តស្តាប់ទេ តាំងពីក្មេងមក?

ខ៖ គ្មានចូលចិត្តទេ លឺគេច្រៀងអីច្រៀងទៅ ឥលូវនឹងចូលចិត្តតែធម៌ទេ។

ក៖ អូ! អញ្ចឹងអ្នកមីងចូលចិត្តស្តាប់ធម៌ទេសនា។

ខ៖ ចូលចិត្តស្តាប់ធម៌ទេសនា ស្មើម៉ាន់ក៏បើកស្តាប់ដែរអោយតែលឺទល់តែឈប់។

កៈ ហើយអញ្ចឹង នៅក្នុងក្រុមគ្រួសាររបស់អ្នកមីងមាននរណាម្នាក់ដែលគាត់ចេះលេងឧបករណ៍ភ្លេងដែរឬទេ អ្នកមីង?

ខៈ អត់មានផង អត់មានចេះទេកូនចៅទាំងអស់នឹង។

កៈ ហើយអញ្ចឹង តើផ្ទះរបស់អ្នកមីងមានលក្ខណៈដូចម្ដេចដែរ ពេលនៅក្មេងៗ?

ខៈ នៅពីក្មេងផ្ទះតូច។

កៈ ផ្ទះទាបនៅនឹងដី ឬមួយផ្ទះខ្ពស់ដែរ អ្នកមីង?

ខៈ មិនទាបទេ វាខ្ពស់តែគ្រាន់តែវាតូច។

កៈ ហើយអញ្ចឹង ប្រក់ដំបូលអីគេដែរ អ្នកមីង?

ខៈ ដំបូលប្រក់ដែក ក្ដៅពេកបកដែកចេះប្រក់ចំបើងវិញអោយវាត្រជាក់។

កៈ ហើយអញ្ចឹង ផ្ទះមួយនឹងនរណាគេជាអ្នកធ្វើដែរ ផ្ទះតូចនឹង?

ខៈ ផ្ទះតូចនឹងពីដើមធ្វើទាំងអស់គ្នាពីនាក់តាហើយនឹងយាយនឹងណា។

កៈ អូ! តាយាយគាត់អ្នកធ្វើដោយសារយើងអត់មានឪពុកម្ដាយ។ ហើយអញ្ចឹង តើគាត់បានឧបករណ៍ធ្វើផ្ទះដូចជាឈើអីនឹង មកពីណាដែរ អ្នកមីង?

ខៈ ទិញគេកាលនោះ។

កៈ អូ!គាត់ទិញគេ គាត់អត់បានទៅកាប់ដោយខ្លួនឯងទេ។

ខៈ គាត់អត់បានទៅកាប់ទេ គាត់ចាស់ដែលហើយនឹង។

កៈ ហើយអញ្ចឹងសំរាប់ផ្ទះនឹងតាយាយរបស់អ្នកមីងគាត់ជួលគេអោយធ្វើអោយ ឬមួយគាត់បានធ្វើដោយខ្លួនឯង?

ខៈ កាលនោះគាត់ជួលគេអោយធ្វើ។

កៈ ហើយអញ្ចឹង តើអ្នកមីងមានជំនាញដែលបន្តវេនពីក្រុមគ្រួសារដូចជា វេញវល្លិ៍ផ្ដៅ ឬក៏ធ្វើស្ករត្នោត ឬក៏ត្បាញក្រមា ហូល ផាមួងអីទេ អ្នកមីង?

ខៈ ខ្ញុំអត់ចេះត្បាញទេ កាលប្ដីរបស់ខ្ញុំគាត់នៅរស់គាត់ឡើងត្នោតដែរតានឹង។

កៈ អូ! ប្តីរបស់អ្នកមីងគាត់មានជំនាញឡើងត្នោត។

ខៈ គាត់ឡើងត្នោត កាលនឹងគាត់ឡើងអោយសហករ ហើយបន្ទាប់មកគាត់ឡើងខ្លួនឯង។

កៈ អញ្ចឹង បន្ទាប់អស់ពីគាត់មកអត់មានអ្នកចេះទេ អ្នកមីង?

ខៈ វាលែងធ្វើកូនវាចេះដែរ គេទៅរកស៊ីនៅប្រទេសថៃបានលុយច្រើនជាង។

កៈ ហើយអញ្ចឹង ពេលសម័យសង្គ្រាម តើអ្នកមីងនៅកន្លែងណាដែរ អ្នកមីង?

ខៈ ពេលសម័យសង្គ្រាមខ្ញុំនៅនឹងតើ។

កៈ អញ្ចឹង គេអត់មានបានជំលៀសអ្នកមីងទៅកន្លែងផ្សេងទេ?

ខៈ ទៅ ទៅដល់អីខេត្តកំពង់ធំ ភូមិតាំងក្រសាំង គេកៀរទៅនោះ។

កៈ ហើយអញ្ចឹងពេលសម័យសង្គ្រាមនឹង តើអ្នកមីងមានអាយុប៉ុន្មានឆ្នាំហើយអ្នកមីង?

ខៈ មិនដឹងប៉ុន្មានទេ ភ្លេចទៅហើយ។

កៈ តែអ្នកមីងចាស់ហើយ ឬមួយនៅក្មេងទេ អ្នកមីង?

ខៈ ទេ ចាស់ដែរហើយនឹង។

កៈ ហើយអញ្ចឹង ពេលសម័យសង្គ្រាមនឹងគេបានអោយអ្នកមីងធ្វើអ្វីខ្លះដែរ អ្នកមីង?

ខៈ ពេលសម័យសង្គ្រាមនឹង ពេលនៅនឹងផ្ទះនឹងគេអោយខ្ញុំអោយបាយជ្រូក បាយទា តែពេលវាពងមកគេអ្នករើសទេ យើងបានតែមើលហើយអោយចំណីទេ តែយើងហ៊ានយករបស់គេនឹងគេយកយើងទៅវាយចោលហើយ គេមិនអោយយើងរើសទេ គេអោយតែយើងអោយបាយវាស៊ីទេ។

កៈ ហើយអញ្ចឹង សំរាប់ជីវិតរបស់អ្នកមីងមានពេលដែលលំបាកជាងគេទេ អ្នកមីង?

ខៈ មាន ពីក្មេងនឹងវាពិបាកណាស់ វាពិបាកអត់ម៉ែអត់ឪ មកយកប្អូនមកហើយគេចាត់តាំងអោយទៅទ័ព ហើយប្អូនស្លាប់នៅឯសមរភូមិ (សមរភូមិ មានន័យថាកន្លែងទ័ពច្បាំងគ្នា) នឹងទៅ ហើយមកប្អូនទីបីនឹងទៅរកស៊ី ហើយគេបាញ់សំលាប់ទៅ បែកបាក់គ្នានៅតែបងប្អូនពីរនាក់នឹងរាល់ថ្ងៃ។

កៈ ហើយអញ្ចឹង តើអ្នកមីងធ្លាប់មានបទពិសោធន៍ណាល្អៗនៅក្នុងជីវិតទេ ដូចជា រៀបការកូន ឬក៏បុណ្យទាននៅនឹងផ្ទះ ធ្លាប់មានទេ អ្នកមីង?

ខ៖ ចាំ! មាន រៀបការកូនអស់ប្រាំមួយ ប្រាំពីរ ប្រាំបីហើយ រៀបការក្មួយនោះអស់ពីរនាក់ ហើយរៀបការកូនខ្លួនឯងនឹងប្រាំមួយនាក់ ចឹងរៀបការអស់ប្រាំបីដង។

ក៖ ហើយអញ្ចឹង ទាំងអស់នឹងសុទ្ធតែអ្នកមីងរៀបចំខ្លួនឯងទាំងអស់?

ខ៖ សុទ្ធតែរៀបចំខ្លួនឯងរហូត ហើយបុណ្យនឹងធ្វើរាល់តែឆ្នាំ។

ក៖ អញ្ចឹងបានធ្វើបុណ្យច្រើនណាស់! ហើយអញ្ចឹង ពេលដែលអ្នកមីងនៅក្មេងធ្លាប់មានសេចក្តីសង្ឃឹមថា ពេលធំឡើងចង់ធ្វើអ្វីមួយទេ អ្នកមីង?

ខ៖ ចង់ទៅមិនរួចដោយសារមិនចេះអក្សរនឹងតែម្តង។

ក៖ តែអ្នកមីងធ្លាប់មានបំណងដែរ មែនទេ?

ខ៖ មានបំណងដែរ តែគ្រាន់តែទៅមិនរួចនឹងឃើញថាយើងវាអត់ចេះអក្សរ។

ក៖ ហើយអញ្ចឹង តើអ្នកមីងចង់ធ្វើអ្វីដែរ អ្នកមីង?

ខ៖ ចង់ទៅធ្វើការនេះនោះទៅណា។

ក៖ ហើយអញ្ចឹងសំរាប់ចុងក្រោយ បើសិនជាអ្នកមីងចង់ផ្តាំផ្ញើរទៅកាន់ជំនាន់ក្រោយ តើអ្នកមីងនឹង ផ្តាំផ្ញើរអ្វីខ្លះ អ្នកមីង?

ខ៖ ផ្តាំផ្ញើរទៅកាន់កូនចៅអោយប្រឹងរៀនអោយចេះ អោយបានធ្វើការធ្វើងារនឹងគេ អោយបានទៅរកស៊ីនៅប្រទេសគេ កុំអោយពិបាកដូចខ្ញុំចឹង វាអត់ចេះចឹងណា។

ក៖ ហើយអញ្ចឹង បើសិនជាអ្នកមីងចង់អោយពួកគាត់ជៀសវាង តើអ្នកមីងចង់អោយពួកគាត់ជៀសវាងពីអីគេខ្លះដែរ អ្នកមីង?

ខ៖ អោយជៀសវាងពីថ្នាំញៀន ជៀសវាងពីកោងកាច សំដីកាចសាហាវនឹងណា អោយស្លូតបូតដាក់គ្នា រាប់អានគ្នា។

ក៖ ចុងក្រោយអរគុណច្រើនហើយអ្នកមីងសំរាប់ពេលវេលារបស់អ្នកមីងដែលបានអោយខ្ញុំសម្ភាសន៍ពីខ្សែជីវិតរបស់អ្នកមីង ហើយចុងក្រោយសូមជូនពរដល់អ្នកមីងមានសុខភាពល្អ មាន កំលាំងមាំមួន ជៀសផុតពីជម្ងឺទាំងឡាយ ហើយសូមជូនពរដល់កូនចៅរបស់អ្នកមីងទាំងអស់គ្នាថា ពួកគាត់មានសុខភាពល្អ មានកំលាំងមាំមួន មានប្រាជ្ញាវៀងវៃ ហើយសូមអោយកូនចៅរបស់អ្នកមីងដែលនៅប្រទេសគេអីនឹង ធ្វើកិច្ចការងាររាល់ថ្ងៃនឹងអោយចេះតែបានសេចក្តីសុខសេចក្តីចំរើន កុំ

អោយមានបញ្ហាអីកើតឡើង ដើម្បីគាត់មានលទ្ធភាពជួយដល់អ្នកមីង ដើម្បីបន្តក្នុងជីវិតរបស់អ្នកមីង អោយមានសេចក្តីសុខ សេចក្តីចំរើន កុំអោយពិបាកដូចពីដើមទៀត។ អរគុណច្រើន អ្នកមីង។